KhmerPost USA
Advertising: PA/NJ/NY: (267) 253-3947/ CT: (860) 461-3687
MA/RI: (978) 656-8141/ (781) 244-0522

Vol 06 Issue 119 Dec. 8th- 20th. 2012

មាតិការឿង | ទំព័រ

១-គណៈកម្មាធិការព្រំដែនកម្ពុជា..............០៥
២-ក្រុមអ្នកតវ៉ា&កម្មវិធីសមធម៌ត្រូវ,ខេមបូឌា ដេលី.....០៦&០៧
៣-ក្តួបុលរីណេតរាយការណ៍ពីបរិស្ថាន..............០៨
៤-ប្រវត្តិរូបសិល្បករនិពន្ធវើដោះប្រជាពលរដ្ឋខ្មែរ..............១៥
៥-ទៅមើលបាល់ទាត់នៅសាលាឯកជន..............១៩
៦- ដំណើរកម្សាន្តខេត្ត-ក្រុងនៅតាម..............២០

32 Wamesit St., Lowell, MA 01852. Phone-Fax (978) 656 8141 www.khmerpost.us

# ឡឥដ្ឋគ្មានផ្សែងរបស់លោកយ៉ារី

**ឡូវែល:** វត្ថុធាតុធ្វើពីដីឥដ្ឋមួយចំនួនជាស្នាដៃសិល្បៈរបស់លោក យ៉ារី លីវ៉ាន ជាអតីតសាស្ត្រាចារ្យមហាវិទ្យាល័យសូន្យរូប និងបច្ចុប្បន្នជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យ មីឌិលសិច បានត្រូវបញ្ចូលក្នុងឡអុសតែគ្មានផ្សែង កាលពីថ្ងៃសៅរ៍ទី២៤ ខែវិច្ឆិកា ហើយបានដុតបំប៉នភ្លើងកំដៅ២០០០អង្សាមុននឹងយកចេញមកវិញនៅថ្ងៃអង្គារបន្ទាប់មកបានជារបស់ប្រើប្រាស់ប្រណីតដូចជា កែវ ចាន ផ្តិលខាត់ ថូ ប៉ាន់តែ រូបសត្វនាគ ឬដីរ៏...ចំនួនប្រមាណជា ១០០គ្រឿង ។ ពីដីឥដ្ឋទៅជាវត្ថុប្រើប្រាស់ លោក យ៉ារី បានប្រើបច្ចេកទេសសូន្យរូបបុរាណរបស់ខ្មែរបានប្រើតាំងពីជំនាន់មុនសម័យអង្គរ ហើយបច្ចេកទេសបានបាត់បង់តាមផ្លូវនៃពេលវេលាដ៏វែងឆ្ងាយ និងបច្ចេកវិទ្យាថ្មីៗ ឥឡូវនេះលោក យ៉ារី លីវ៉ាន បានធ្វើឱ្យរបស់ប្រើប្រាស់ធ្វើដោយដៃក្លាយជាវត្ថុសិល្បៈគ្មានពីរដូចគ្នា ឱ្យកើតឡើងវិញបានជាមួយនិងឡឥដ្ឋដុតអុសតែគ្មានផ្សែងតាំងទីនៅក្បែររបងសារមន្ទីរសួនឧទ្យានជាតិនៃទីក្រុងឡូវែល ។

លោក យ៉ារី បានផ្តើមធ្វើចម្លាក់ដីឥដ្ឋជាច្រើនមុខរួចហើយលាបពណ៌ដោយថ្នាំពិសេសប្រើជាមួយដីឥដ្ឋមុននិងបញ្ចូលក្នុងឡរបស់លោក រួចហើយបិតឡនោះឱ្យជិតមិនឱ្យខ្យល់ចូលបានក្រៅតែពីបង្អួចសម្រាប់បញ្ចូលអុសបំប៉នភ្លើង។ ក្រុមអ្នកស្ម័គ្រចិត្តមានក្រុមគ្រួសារមិត្តភ័ក្តិជាសិល្បៈករដូចគ្នាជាដើម ។ល។ បានមកជួយពុះអុស តទៅទំព័រទី ១២






# ស្វាគមន៍ខ្មែរផុសស.រ.អា នៅញូអិនគ្លិន



**ដោយពិន សំខុន នាយកការផ្សាយខ្មែរផុស ស.រ.អា**

សមាគមខ្មែរនៅឡូវែល មាសាឈូសែតបានសម្តែងការស្វាគមន៍ដ៏កក់ក្តៅដល់វត្តមានសារព័ត៌មានខ្មែរផុស ដែលផ្តើមផ្សព្វផ្សាយតាំងពី២ ឆ្នាំមកហើយនៅតំបន់ញូអិនគ្លិន ឥឡូវមកតាំងនៅក្រុងឡូវែលជាបន្តទៅទៀត ។

ដូចគ្នានេះដែរ សមាជិកសហគមន៍ខ្មែរក៏បានបង្ហាញមនោសញ្ចេតនារីករាយ នឹងបានកាសែតខ្មែរផុសចូលមកបំរើវិស័យព័ត៌មានខ្មែរ អាមេរិកាំងនៅតំបន់ខ្លួនដូចគ្នាដែរ ។ ខាងកុណិចកិក នឹងលីនវីវៃ ក៏មានអបអរសាទរដល់វត្តមានយើងដែរ ។

ខ្មែរផុសសូមថ្លែងអំណរគុណចំពោះតំណាង និងសមាជិកសហគមន៍ដែលបានសម្តែងស្វាគមន៍ គឺជាការលើកទឹកចិត្តដល់ខ្មែរផុស នឹងសហការីឱ្យរឹតតែពង្រឹងគុណភាពសំរាប់បំរើការអានព័ត៌មាន ដែលជាគោលការណ៍ គឺលើកតម្កើងសង្គមខ្មែរ ដោយសោភ័ណភាព ដោយគុណភាពសរសេរអក្សរខ្មែរ ដោយគំនិតសិក្សា គំនិតរួមសម្បាច់ ដោយការផ្តល់ព័ត៌មានពិត ដោយការផ្តល់ទស្សនៈប្លែកៗខុសៗគ្នា ដែលជាសិទ្ធិចំបងរបស់មនុស្ស ។

លោកអ្នកបានបង្ហាញថា "សង្គមសេរីត្រូវការព័ត៌មានសេរី" **តទៅទំព័រទី ០៦**



គណៈកម្មការនាយកសមាគមខ្មែរនៅឡូវែលផ្តល់ការស្វាគមន៍ដល់តំណាងខ្មែរផុស

# ឆាកល្ខោននយោបាយរវាងលោក ហ៊ុន សែន និងយុវជនរបស់បក្សប្រឆាំងម្នាក់



**ដោយ: អ៊ឹម លឿម**

ប្រធានចលនាយុវជននៃ គណបក្ស សម រង្ស៊ី គឺ លោក សួង សុភណ្ឌ កាលពីពេលថ្មីៗកន្លងមកនេះ បានដាក់ខ្ញុំពាក្យបណ្តឹងប្តឹងទៅលោក ហ៊ុន សែន ពីបទឃាតកម្មគិតទុកជាមុន ដែលបានធ្វើឱ្យប្រជាពលរដ្ឋខ្មែរស្លាប់ចំនួន៣៥០នាក់ និងរងរបួសជាង៤០០នាក់ នៅលើស្ពានកោះពេជ្រ ដែលពាក្យបណ្តឹងនេះត្រូវបានគេចាត់ទុកថា ជាសំណុំរឿងដ៏រសើបព្រោះនេះជាលើកដំបូងដែលមានយុវជនហ៊ានប្រើប្រាស់នូវសិទ្ធិជាពលរដ្ឋ ក្នុងប្រព័ន្ធតុលាការទោះបីជាការដឹងថា តុលាការក្នុង **តទៅទំព័រទី០៧**



Accepting New Clients
សូមស្វាគមន៍ដល់ភ្ញៀវគ្រប់ប្រភេទ
Immigration • Divore • Auto Crash
អន្តោប្រវេសន៍ គ្រោះថ្នាក់រថយន្ត លែងលះប្តីប្រពន្ធ
Law Office of Thomas Stylianos Jr. •287 Appleton St. Lowell MA 01852
ការិយាល័យ មេធាវី ថូម៉ាស ស្តាលីយ៉ាណូស
Call: Sophea or Thomas សូមទូរស័ព្ទមក: សោភា, ឬធំ
978-459-5000 or 800-308-3766
Only Licensed in Massachusets

world tv™

# ភ្ជាប់ទៅកាន់ប្រទេសកម្ពុជា នារដូវរងានេះក្នុងតម្លៃកាន់តែទាប

បន្តភ្ជាប់ទៅកាន់ប្រទេសកម្ពុជានារដូវរងានេះជាមួយ **WorldTV** ។ មើលប្រដាល់គុនខ្មែរ បទចម្រៀងល្បីៗ និងការសម្ដែងតន្ត្រីបន្តផ្ទាល់តាមកម្មវិធីតន្ត្រីសម័យថ្មី ភាពយន្ត ព័ត៌មាន និងច្រើនទៀតនៅលើទូរទស្សន៍ **CTN** និង **TVK** ។

## សូមមកទទួលនូវការជាវចំនួន 3 ខែជាមួយទូរទស្សន៍ CNT និង TVK



កញ្ចប់ផ្កាយរណប
**WorldTV**
(មានតម្លៃ $154)

+

ការដាក់ឱ្យដំណើរការ

+

ទទួលបានជិត 100
ប៉ុស្តិ៍ផ្សាយដោយឥតគិតថ្លៃ

ទាំងអស់ត្រឹមតែ **$175**



ការផ្ដល់ជូនបញ្ចប់នៅថ្ងៃទ **31** ខែ មករា ឆ្នាំ **2013** ។
សូមទូរស័ព្ទមកលេខ **1.888.802.8150** និងបញ្ជាក់អំពីលេខកូដការផ្សព្វផ្សាយលេខ **53D** នាថ្ងៃនេះ!
ឬចុះឈ្មោះតាមរយៈ:
**WWW.GLOBECASTWTV.COM/HOLIDAY**



ជួបយើងខ្ញុំតាម f: WorldTV International Television t: @WorldTVUSA

ការផ្ដល់ជូន/សេវាកម្មមានតែនៅក្នុងសហរដ្ឋអាមេរិកតែប៉ុណ្ណោះ ។ ការផ្សព្វផ្សាយ មានសុពលភាពសម្រាប់តែអតិថិជនថ្មីប៉ុណ្ណោះ ។ ការចុះឈ្មោះបង់ថ្លៃដោយស្វ័យប្រវត្តិក្នុងរយៈពេល 6 ខែត្រូវបានតម្រូវ ។ ការដឹកជញ្ជូន ការទទួលខុសត្រូវ ពន្ធដារមាន និងថ្លៃដំឡើងមិនត្រូវបានរាប់បញ្ចូល ។ ការកម្រិតផ្សេងៗអាចត្រូវអនុវត្ត ។ សូមចូលមើល www.globecastwtv.com សម្រាប់បញ្ជីអ្នកបច្ចេកទេសដំឡើងជំនាញឯករាជ្យ នៅក្នុងតំបន់របស់អ្នក ។ ការផ្ដល់ជូនមិនអាចឱ្យបង្វិលជាប្រាក់ជូនវិញបានទេ ។ ការផ្ដល់ជូនមានសុពលភាពរហូតដល់ថ្ងៃទី 31 ខែ មករា ឆ្នាំ 2013 ។

# មេធាវីថីមាសស្ទីលីអាណូស

- ជួយធ្វើតាក់ឋោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

# Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

គណៈកម្មាធិការព្រំដែនកម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
Comité des Frontières du Cambodge ( C F C ) Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

# គណកម្មាធិការព្រំដែនកម្ពុជាប្រទេសបារាំង និងក្នុងពិភពលោក

បារីសថ្ងៃទី ២០ តុលា ឆ្នាំ២០១២

## ផលវិបាកនៃសន្ធិសញ្ញាដែលបានចុះជាមួយប្រទេសវៀតណាម

ក្នុងឆ្នាំ១៩៧៩-១៩៨២-១៩៨៣-១៩៨៥-២០០៥



សៀន ប៉េងសែ

ក/ សន្ធិសញ្ញាចុះថ្ងៃទី ១៨ កុម្ភៈ ១៩៧៩ (តពីលេខមុន)

(មានតនៅលេខក្រោយ)

ដោយឧត្តមក្រុមប្រឹក្សាជាតិទទួលបន្ទុកកិច្ចការព្រំដែនជាជំនួសវិញ ព្រមទាំងតែងតាំងខ្លួនលោកជាប្រធានខ្លួនឯងទទួលខុសត្រូវចំពោះខ្លួនឯង ជារដ្ឋមន្ត្រីទី១ខ្លួនឯង ។ បានសេចក្ដីថា ខ្លួនលោកជាចាងហ្វាងកាត់ក្ដីផងជាកូនក្ដីផង ដូចពាក្យគេតែងនិយាយថាសប្បុរសធម៌ត្រូវគិតខ្លួនឯងមុនសិន...។

នៅថ្ងៃទី១០ តុលា ឆ្នាំ ២០០៥ លោក ហ៊ុន សែន បានចុះហត្ថលេខាជាមួយក្រុងហាណូយលើ "សន្ធិសញ្ញាបពេញបន្ថែមលើសិទ្ធិសញ្ញាឆ្នាំ ១៩៨៥" ។ សន្ធិសញ្ញានេះបានទទួលការអនុម័តពីសភាជាតិ នៅថ្ងៃទី១១ ខែវិច្ឆិកា ពីព្រឹទ្ធសភា នៅ ថ្ងៃទី២៩ ហើយនៅថ្ងៃទី៣០ ខែដដែលបានទទួលសច្ចាប័នពីព្រះ-មហាក្សត្រជាបន្តទៀត ។ បន្ទាប់មកភ្លាមនោះ លោក ហ៊ុន សែន បានសរសើរខ្លួនឯងពីសិទ្ធិសញ្ញាបំពេញបន្ថែមនេះ ព្រោះថា សន្ធិសញ្ញានេះបានបើកឱកាសឱ្យមានការទទួលស្គាល់ "ភាពត្រឹមត្រូវតាមច្បាប់" មួយបែបដោយស្វ័យប្រវត្តិក្នុងសភាពខ្វាក់ដោយគ្មានការពិគ្រោះគ្នាជាមុនសិនដោយស្ថាប័នជាតិនានា ។

សន្ធិសញ្ញាទាំងអស់នេះដែលបានរៀបចំឡើងក្នុងពេលដែលប្រទេសកម្ពុជាកំពុងកាន់កាប់ដោយប្រទេសវៀតណាមសុទ្ធសឹងធ្លាក់ក្នុងមោឃភាពទាំងអស់ដោយសារផ្ទុយនឹងបទបញ្ញត្តិនៃអនុសញ្ញាក្រុងវៀន ឆ្នាំ១៩៦៩ ស្ដីពីសិទ្ធិក្នុងសន្ធិសញ្ញា ។ មួយវិញទៀតត្រូវរំលឹកថា ការផ្ដល់សច្ចាប័នលើសន្ធិសញ្ញានេះ គឺធ្វើឡើងនៅក្រោមសំពៀតនៃការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដែលលោក ហ៊ុន សែន បានធ្វើទៅលើគ្រប់នរណាដែលហ៊ានជំទាស់ : គំរាមសម្លាប់ការចាប់ចងការឃុំឃាំងដោយឥតជំនុំជំរះ រហូតដល់គំរាមថានឹងរំលាយរាជានិយមចោលប្រសិនបើព្រះមហាក្សត្រមិនយល់ព្រមផ្ដល់សច្ចាប័ននេះ ។ល។ ការបង្ខិតបង្ខំដែលលោក ហ៊ុន សែន បានប្រើដើម្បីជំរុញឱ្យអ្នកទទួលខុសត្រូវជាន់ខ្ពស់របស់ប្រទេសផ្ដល់សច្ចាប័នដល់សន្ធិ-សញ្ញានេះ ជាប្រត្យក្សបានធ្វើឱ្យសន្ធិសញ្ញានេះធ្លាក់ក្នុងមោឃភាពដោយខ្លួនឯង ។ នេះជាគោលការណ៍ទូទៅនៃច្បាប់ដែលអនុសញ្ញាទីក្រុងវៀន ឆ្នាំ១៩៦៩ ស្ដីពីសន្ធិសញ្ញាបានយោងទៅលើមាត្រា៥១ អនុសញ្ញាដែលប្រទេសកម្ពុជាក៏ជាសមាជិកដែរ ។

**ការទទួលខុសត្រូវរបស់អាជ្ញាធរខ្មែរចំពោះបញ្ហាទាំងអស់នេះ**

សន្ធិសញ្ញាខុសច្បាប់ និងមិនស្មើភាពគ្នាទាំងនេះ ត្រូវតែបញ្ចប់តាំងពីរដ្ឋាភិបាលទី១ ឆ្នាំ១៩៩៣មកម្ល៉េះ ស្របទៅតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីសស្ដីពីប្រទេសកម្ពុជាថ្ងៃ២៣ តុលា ឆ្នាំ ១៩៩១ និងស្របទៅតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៣ (មាត្រា៥៥) ។

តែខុសពីអ្វីដែលគេបានស្មានទុកសន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងអស់នេះ ត្រូវបានទទួលស្គាល់ដោយគណៈកម្មការចំរុះខ្មែរ -យួននៅថ្ងៃទី ២៧ ខែមិនា ឆ្នាំ ១៩៩៩ ទៅវិញ និងយល់ព្រមដោយរដ្ឋាភិបាលរួបរួមនៅថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០០០ ដែលជាការមួយផ្ទុយនឹងធម្មនុញ្ញរបស់ប្រទេសកម្ពុជា (មាត្រា៥២) ទាំងស្រុង ។ ជាការពិតនេះប្រាកដជាចេតនារបស់របស់រដ្ឋាភិបាលដោយឥតប្រកែកបាន ដោយហេតុថា នៅក្នុងថ្ងៃ ៣១ ខែ កក្កដា ឆ្នាំ ២០០០ ឆ្លើយតបទៅនឹងលិខិតមួយរបស់ព្រះមហាក្សត្រ លោក ហ៊ុន សែន បានផ្ដល់ពាក្យសំអាងមួយបែបដែលពុំអាចយល់បាន :

"...យោងតាមស្ថានភាពសព្វថ្ងៃនេះ និងលើចំណុចពីរដែលមានចែងខាងលើស្រាប់ជាការដែលមិនសមរម្យឡើយសំរាប់រដ្ឋាភិបាល បើនឹងថ្លែងជាផ្លូវការណ៍ក្នុងពេលនេះ និងដោយចំហរដាក់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងនេះដែលបានធ្វើជាមួយនឹងប្រទេសវៀតណាមក្នុងមោឃភាព ដើម្បីទុកឱ្យគណៈកម្មាការចំរុះខ្មែរ-វៀតណាមបន្តការចរចារគ្នាដែលមានភាពយ៉ាប់បំផុតនេះ រហូតបានទទួលលទ្ធផលល្អ ប្រសើរ" ។

តែលទ្ធផលដែលទទួលបានមកវិញ គឺមិនអាចនឹងអភិវឌ្ឍមានជាងនេះទៅទៀតនោះឡើយ ។

**តទៅលេខក្រោយ**






ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងថ្មីៗសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បត្តិ៍ ទី០៦ ខែធ្នូ ឆ្នាំ២០១២

# ក្រុមអ្នកតវ៉ានិងការបណ្តេញចេញមានកាន់ច្រើន នៅខាងក្រៅអគារការិយាល័យនាយករដ្ឋមន្ត្រី

**ខេមបូឌា ដេលី**

ក្រុមអ្នកតវ៉ាប្រឆាំងនិងការបណ្តេញចេញពីលំនៅដ្ឋាន បានធ្វើបាតុកម្មនៅខាងក្រៅអគារការិយាល័យរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាការធ្វើបាតុកម្មលើកទី២នៅសប្តាហ៍នេះ និងបានប្រគល់ញត្តិជាច្រើនទៅទីស្តីការគណៈរដ្ឋមន្ត្រីដោយបានអំពាវនាវសុំឱ្យលោកនាយករដ្ឋមន្ត្រីហ៊ុនសែន ជួយដោះស្រាយវិវាទដីធ្លីរបស់ពួកគាត់ជាច្រើនកន្លែង។

ក្រុមអ្នកតវ៉ាប្រហែលចំនួន១០០នាក់ចេញមកពីសហគមន៍ប្រាំបួនដាច់ដោយឡែកពីគ្នានៅទូទាំងរាជធានីភ្នំពេញ ដែលសហគមន៍នីមួយៗត្រូវបានបណ្តេញចេញ ឬកំពង់ប្រឈមមុខនិងការបណ្តេញ។

ក្រុមអ្នកតវ៉ាទាំងនេះត្រូវបានក្រុមនគរបាលរារាំងមិនឱ្យចូលក្នុងបរិវេណអគារនេះ ប៉ុន្តែក្រោយមកត្រូវបានអនុញ្ញាតិឱ្យបញ្ជូនតំណាងមួយចំនួនចូលទៅទីស្តីការគណៈរដ្ឋមន្ត្រីតាមទ្វារមួយទៀតដើម្បីប្រគល់ញត្តិរបស់ពួកគេ។

ក្នុងចំណោមអ្នកតវ៉ាទាំងនេះ អ្នកស្រីច្រៃ នីម ជាគ្រួសារមួយចំណោម១៨២គ្រួសារដែលប្រឈមនិងការបណ្តេញចេញពីផ្ទះសម្បែងស្ថិតនៅក្បែរអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ។

រដ្ឋាភិបាលបានបដិសេធមិនផ្តល់សំណងដល់គ្រួសារទាំងនេះទេ ទោះបីជាគ្រួសារទាំងនេះ មានប័ណ្ណស្នាក់នៅដែលអាជ្ញាធរចេញឱ្យក៏ដោយ។

អ្នកស្រីនិយាយថា"ខ្ញុំមិនចេញពីផ្ទះទេប្រសិនបើមិនមានសំណងសមរម្យនោះ"។ លោក ប៊ុន អ៊ុយ រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីបានបញ្ជាក់ថា លោកបានទទួលញត្តិកាលពីម្សិលមិញ ហើយមានប្រសាសន៍ថា លោកនឹងបញ្ជូនញត្តិទាំងនោះទៅខុទ្ទកាល័យរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ៕

**ប្រែសម្រួលដោយ ស៊ុំ សុខភុំ**

## តមកពីទំព័រទី ១ ស្វាគមន៍ខ្មែរផុសស.រ.អា...

វីឯសង្គមខ្មែរដែលមានវប្បធម៌ថ្មីថ្មើងមួយនឹងគេដែរត្រូវការព័ត៌មានសេរី ឯករាជ្យ ជាភាសាខ្មែរ ដូចអ្នកឯទៀត ដែលរស់នៅ ស.រ.អា នេះដែរ ។ ហេតុដូចនេះហើយបានជាលោកអ្នកឱ្យតម្លៃខ្ពស់ដល់សារព័ត៌មានខ្មែរផុស ដែលជានិច្ចជាកាលប្រើរិជ្ជាជីវៈសាកលនៃសារព័ត៌មានមកអនុវត្តន៍ ក្នុងការបំរើលោកអ្នកនៅឆ្នេរខាងកើតនៃ ស.រ.អា ជារៀងរហូតមក។

ដូច្នេះសូមលោកអ្នកបញ្ចេញយោបល់ប្រាប់យើងខ្ញុំនៅពេលមានអ្វីផ្តូផ្តងបានកើតឡើង ដើម្បីឱ្យការបំរើវិស័យព័ត៌មានដល់លោកអ្នកក្លាយជាការពេញចិត្ត ពេញថ្លើមបាន។ សូមអរគុណ!



សមាជិកសភាក្រុងលីន សម្តែងការស្វាគមខ្មែរផុស



ថ្នាក់ដឹកនាំសហគមន៍នៅម្សូវ៉េលអបអរនិងវត្តមានខ្មែរផុស




សហគមន៍ខ្មែរនៅកូណិទិកិតផ្តល់វេទិការឱ្យខ្មែរផុស

# Cambodia Retains Its Reputation for Corruption

By Lauren Crothers
CAMBODIA DALY

Cambodia continues to rank among the most corrupt countries in the world and much needs to be done to enforce the Anti-Corruption Law and investigate allegations of corruption, Transparency International (T.I) Cambodia said yesterday.

According T.I.´s 2012 Corruption Perceptions Index (CPI), Cambodia ranked 157th among 176 countries and territories listed, with a score of just 22 out of 100-a slight improvement on last year´s ranking of 164.

"The CPI score for 2012 indicates that Cambodia is still perceived as a highly corrupt country," T.I. said in a statement.

"For corruption to be reduced in Cambodia there is a need for further progress in the enforcement of the Anti-Corruption Law and an increase in the capacity and outreach of the Anti-Corruption Unit (ACU) to effectively investigate corruption cases and bring them to court."

Transparency also said the government needs to pass an Access to Information Law in order to make the state budget and other important financial decisions made by the government more transparen and "improve the effectiveness of the anti-corruption law enforcement."

The Central African Republic and war-torn Syria fared better than Cambodia on the index, with joint rankings of 144. Mexico, in which a long-running and grisly drug war has claimed thousands of lives, also rated higher, ranking 105th in the world. Regionally, only Laos (160/21) and Burma (172/15) fared worse than Cambodia.

Neighboring Thailand was ranked 88 th with a score of 37, while Vietnam came 123rd with 31 points. Among the Asean member nations, Brunei was judged the " cleanest," with a rank of 46th and score of 55.

Speaking at a press conference to launch the report, Preap Kol, executive director of T.I.´s Cambodia office, likened corruption to HIV, saying that it infected many levels of society from education and health services to human rights and the judicial system.

Mr. Kol added that Cambodians "should have access to decent health care and education without paying bribes and fees."

In a statement, T.I. Board of Directors Chairman Rath Sophal said law enforcement is crucial to minimizing corruption.

"Fighting corruption requires unwavering political will and determination of the government in terms of having an adeuate legal framework and governance mechanisms that minimize the opportuni ty for corruption along with consistent enforcement," he said.

Since its inception in 2010, the ACU has received hundreds of complaint detailing allegations of corruption, though only four arrests have been made so far. The most high profile of the arrests was Moek Dara, former head of the National Authority for Combating Drugs, who is seving life in prison on a raft of drug trafficking and bribery charges.

When asked how the ACU could improve, Mr. Kol said it is suffering from a lack of capacity.

"They don´t have the full capacity to investigate those cases," Mr. Kol said. He also said he questioned the indepen dence of the unit, which once had a statue of Prime Minister Hun Sen in its court yard, but removed the effigy as it apparently displeased the prime minister.

Mr. Kol said corruption also impacted the economic sector and investment in particular. "If a company pays a bribe, they can be subject to sanctions in their own countries," he said.

Council of Ministers spokesman Phay Siphan said the T.I. scorecard results were encouraging, but not reflective of the situation on the ground.

"I hope everyone on Earth understands that Cambodia is in a state of transformation," he said. "We are reforming throughout the hierachy of the government agencies. We should reform because the government will be a better service provider. That´s our goal."

Mr. Siphan cited the ACU and the Anti-Corruption Law as examples of the effort the government has made to clean up graft, but said that all levels of society from government to NGOs needed to work together to stamp out the problem.

"It´s the government´s intention to fight corruption and change people´s mindsets."

Mr. Siphan also noted that corruption in the U.S., which is ranked 19th on this year´s list, was the primary catalyst for the global financial crisis, but that Washington had a "sophisticated system" to deal with it.

Thun Saray, president of rights group Adhoc, said corruption pervades many tiers of society, but that the "poor and vulnerable" are affected the most.

"It creates more unhappiness of the people, and also creates social instability if we allow this kind of disease," he said. "I think we have to acknowledge it and continue to collaborate to fight this social problem."

David Carter, CEO of Infinity Insurance and president of the Australian Business Association, said Cambodia had come a long way in terms of its develop ment, and that many developing countries wrestle with the problem of corruption.

"If you look at where the place has come from to here, it´s no surprise that corruption still remains an issue," Mr. Carter said. "But it has improved drama tically in that time... and that might not be apparent in the report."



# BUY RITE Pharmacy

Nhà Thuốc Tây 藥房 ឱសថស្ថាន

## 267-297-5879

## ឱសថស្ថាន ថាច់ សូមស្វាគមន៍

- ឱសថការី ដាន់ ថាច់ មានសេចក្តី រីករាយ និងបំរើសុខភាពបងប្អូនក្នុងសហគមន៍ឱ្យបានប្រសើរ ។
- ភ្ញៀវដែលមកទិញថ្នាំតាមវេជ្ជបញ្ជាទាំងថ្មីទាំងចាស់ អាចនឹងត្រូវឆ្នោតទទួលរង្វាន់ ដូចរូបខាងក្រោម ថ្ងៃទី៣១ ខែធ្នូ ២០១២
- យើងជូនកូប៉េយដូចអ្នកឯទៀត
- ចុះថ្លៃពិសេសជូនព្រឹទ្ធាចារ្យ ។

រង្វាន់ចាប់ឆ្នោត ខែធ្នូ




1st PRIZE Samsung 32" LED HDTV




2nd PRIZE Samsung 32" LCD HDTV




3rd PRIZE Sony Playstation 3

- ផ្ញើថ្នាំជូនដល់ផ្ទះដោយឥតគិតថ្លៃ
- ទទួលអ៊ិនស្វិរិនស្ទើរគ្រប់មុខ
- ទទួលបន្តផ្តល់ថ្នាំដែលលោកអ្នកកំពុងប្រើ ទិញមកពីឱសថស្ថានផ្សេងៗ
- តម្លៃថោកៗបំផុត និងមានស្តុកឱសថគ្រប់មុខប្រភេទ
- ផ្តល់សេវាដោយរហ័សទាន់ចិត្ត
- មានឱសថវីតាមីន-ឱសថចិនសែ និងឧបករណ៍ព្យាបាលមុខជំងឺ

**1337 W.Rockland St.Philadelphia, PA 19141(Corner of Old York Rd & Rockland St.)**
**Tel: 267-297-5879 Fax: 267-297-5880**

# Mekong River

VIETNAMESE RESTAURANT

**1120-1124S Front St., Philadelphia, PA 19147**
(Near Washington Ave. - មានកន្លែងចតឡានត្រឹមត្រូវ

**215-467-6100**

# GRAND OPENING 25-5-2012

មានម្ហូបវៀតណាមគ្រប់មុខ

ហ្វើ មី គុយទាវ នំបញ្ចុក បាញ់ហយ

បាយ ម្ហូបបួស ម្ហូបឆា ម្ហូប សម្រាប់ទទួលជាលក្ខណ:គ្រួសារ

ទទួលពិធីជប់លៀងជាលក្ខណ:គ្រួសារ ឬជួបជុំមិត្តភ័ក្រ

B Y O B






## មានភោជនីយដ្ឋានទើបបើកនៅក្នុងសហគមន៍យើង


ភោជនីយដ្ឋាន អង្គរ
Angkor Restaurant
Ben city Plaza
ថ្មីនំបញ្ចុកណាំយ៉ា និងសៀមរាប
5520 Whitaker Ave, Unit 7 Philadelphia, Pa 19124 Phone: 215.831.1016
អាចបញ្ជាឲ្យធ្វើម្ហូបតៅ "មេញ" បានមានម្ហូប អាមេរិកាំង ម្ហូបអាស៊ីជាដើម
មានធ្វើម្ហូប VG សម្រាប់ អ្នកមិនពិសាសាច់
ភោជនីយដ្ឋាន ម្ហូបខ្មែរ ទើបបើកថ្មី !
នៅហ្វីឡាដែលហៀខាងជើង
សូមអញ្ជើញមកពិសារម្ហូបខ្មែរគ្រប់មុខ ចំអិនដោយចុងភៅខ្មែរស្ទាត់ជំនាញ
នាភោជនីយដ្ឋានធំទូលាយ បំរើម្ហូបខ្មែរពិតប្រាកដដ៏ឈ្ងុយឆ្ងាញ់
អ្នកបំរើភ្ញៀវរួសរាយ មានកន្លែងចតរថយន្តគ្រប់គ្រាន់ !
ម្ហូបដែលចំអិនប្រើពេលយូរ ដូចជាអាម៉ុក សូមបញ្ជាឱ្យបានមុនមួយថ្ងៃ


ហាងមាសរស្មី
SUNSHINE JEWELRY, INC.
215-271-2950
Certified Diamonds & Golds (24K & 18K)
Men & Women Jewelries & Watches
Custom Design & Repairs on Premise
15 Years in Services & Growing Strong
702 Washington Ave. Phila., PA 19147
www.sunshinejewelryonline.com


Phở Hà Saigon
Vietnamese Restaurant
7 days A Week
9am-9pm
B.Y.O.B.
ជាហាងដែលធ្វើ ហ្វើ ឆ្ងាញ់ជាងគេនៅហ្វីឡា-
ដែលភ្ញៀវចុងភៅដែលពូកែធ្វើ ហ្វើ និងម្ហូបផ្សេងៗ
ឯទៀត ត្រូវមាត់ភ្ញៀវគ្រប់ៗរូប ឥឡូវនេះមកធ្វើ
ម្ហូបនៅហាង Phở Hà Saigon
យើងខ្ញុំ ហើយធានាថា ម្ហូបអាហារហាង
និងបំរើលោកអ្នកបានយ៉ាងពេញចិត្តគ្រប់ពេលវេលា
VISA MasterCard DISCOVER
320 W. Oregon Avenue, Suite 1. Philadelphia, PA 19147
Tel: (215) 389-1002 (Inside Oregon Market)


SIM'S
Major Sim Enterprises, Inc.
Home Improvement
ជាងសំណង់តាស៊ីម
License#CS 88569 Registration#153685
978-452-7467 / 978-421-3672 / 978-420-8551
FREE ESTIMATES
60 Middlesex St. (Rte.110) Lowell. MA 01852
FULLY INSURED
ជួសជុល កែលំអរ សង់បន្ថែម
Kitchen ចង្ក្រានបាយ
Livingroom បន្ទប់ទទួលភ្ញៀវ
Bathroom បន្ទប់ទឹក
Bedroom បន្ទប់ដេក
Roofing ដំបូល
Siding ជញ្ជាំង
Window បង្អួច
Door ទ្វារ
Basement ជាន់នៅក្រោមដី
Additions បន្ទប់បន្ថែម
Residential • Commercial • Industrial
ទទួលប្រាក់គ្រប់ប្រភេទ
Bank Loan, Insurance, Compensation, Credit Debit Card, Check &Cash
More information call: 1.978.452.7467
www.simshomeimprovement.com
Boreth@simshomeimprovement.com


Phở BOSTON
Authentic Vietnamese Cuisine
Vietnamese & Chinese Restaurant
ភោជនីយដ្ឋាន
ហ្វើ បូស្តុន
ម្ហូបវៀតណាមពិតប្រាកដ
ភោជនីយដ្ឋានវៀតណាម និង ចិន
បើកទ្វាររាល់ថ្ងៃ
ពីម៉ោង១០ព្រឹក
ដល់១០យប់
Phở BOSTON
144 Shield St. West Hartford CT
Phone.(860) 953-8678
Website.www.phoboston.com


Red Rose
RESTAURANT
ភោជនីយដ្ឋាន
កុលាបក្រហម
ម្ចាស់ថ្មី _ម្ហូបឈ្ងុយឆ្ងាញ់
Mon-Sun
8am -7:30pm
សម្លម្ជូរ គ្រឿង $11.99
*ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
*សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់
(978) 452-5400
Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851


ហាងមាស គីម ង៉ុក
នៅវេសហាតហ្វឺត
KIM NGOC
JEWELRY
មានលក់ជុំ ប្តូរាយ ប្តូរ ប្តូធ្វើប័ណ្ណសំរាប់
អំណោយមានធ្វើប្លែនពន្យាពេលបង់ប្រាក់
-ទទួលសវ៉ាន់បញ្ញើ មានចុះថ្លៃរហូតដល់ ៦៥%
សម្រាប់ ពេជ្រមកពីហុងកុង មានជាងអលង្កា
នៅក្នុងហាងជួសជុលបានភ្លាមៗ
ពេលវេលាបើក : ថ្ងៃច័ន្ទ ដល់ថ្ងៃអាទិត្យ
ពីម៉ោង ១០ព្រឹកដល់៧ល្ងាច
Open: Mon-Sun
10am-7pm
150 Shield Street Plaza. West Hartdord, CT 06110
Tell: (860) 953-5803, Fax:(860)953-5802

តមកពីទំព័រទី ១

## ឡឥដ្ឋគ្មានផ្សែងរបស់លោក...

ផៃភ្លើងដែលបានផ្តើមបញ្ឆេះនាព្រលឹមថ្ងៃសៅរ៍នោះ យ៉ាងព្យាយាម ។ ភ្លើងឆេះសន្ធោសន្ធៅ៩ម៉ោង ក្រោយមកទើបកំដៅឡើងលើស១.០០០អង្សា ដែលធ្វើឱ្យ



ផ្ទៃក្នុងឡផ្តើមឡើងជាក្រហមរងើកភ្លើងទាំងមូលហើយ ហើយពេលនោះ គេផ្តើមមានពន្លឺខ្លះអាចមើលឃើញវត្ថុដែលគេដាក់ក្នុងឡពិនិត្យការប្រែប្រួលរបស់វាបាន ដោយមិនអាចធ្វើអ្វីបានក្រៅតែពិនិត្យមើលពីខាងក្រៅតែប៉ុណ្ណោះ ។ ការចំអិនដីឥដ្ឋលាប



ថ្នាំពីលើបានធ្វើឱ្យវត្ថុដែលដុតទាំងនោះក្លាយទៅជាថ្មកាន់តែរឹងទៅតាមកំណើននៃកម្តៅដែលត្រូវតម្លើង



ឱ្យបានលើសពី២.០០០អង្សា ក្នុងរយៈពេល១០ម៉ោង ជាបន្តទៅទៀត ដែលជាមួយគ្នានោះ ការបញ្ចូល



អុសក្នុងឡត្រូវធ្វើជាប្រចាំមិនឱ្យអន់ភ្លើងឡើយ និងអ្នកកាយផេះក៏ចេះតែកកាយចេញមិនឱ្យស្ទះដំណើរខ្យល់ ដែលបំប៉នរងើកភ្លើងនោះទេ។ មាន "តេស្ទ័រ" ពីរប្រភេទសំរាប់ស្ទង់កម្តៅក្នុងឡថ្ងៃនោះ "តេស្ទ័រ



អេឡិត្រូនិច" ខូចមិនអាចប្រើបានទេតែនៅសល់ "តេស្ទ័រជាចង្កើស៤" ដែលគេអាចដឹងនៅពេលវាផ្តើមរលាយថាពេលនោះកម្តៅមានប៉ុន្មានអង្សាហើយបាន ។



ការដុតបានត្រូវបញ្ចប់នាយប់ជ្រៅថ្ងៃសៅរ៍ នៅពេលដែលកម្តៅឡើងគ្រប់តាមពេលវេលាកំណត់ លោក យ៉ារី បានបិទរន្ធទាំងនោះមិនឱ្យខ្យល់ចូលទៅទៀត ដើម្បីពន្លត់ភ្លើង ហើយទុកឱ្យឡនោះត្រជាក់មកវិញក្នុងរយៈពេល២ថ្ងៃដោយឯកឯង ។ ថ្ងៃអង្គារ៍រសៀលបន្ទាប់មកទើបលោក យ៉ារី បំបែកគំនរឥដ្ឋដែលជាជញ្ជាំងបិទឡបើកជាទ្វារហើយយកវត្ថុចំអិននេះចេញមកបាន ។

ចុងបញ្ចប់លោក យ៉ារី និងក្រុមគ្រួសារព្រមទាំងមិត្តភ័ក្រ្តអាចដកដង្ហើមធូរចិត្តដោយឃើញស្នាដៃចេញពីឡដុតមកវិញ ប្រកបដោយគុណភាពខ្ពស់ដូចបំណង ទោះជាមានការខូចខាតខ្លះក្តីដោយទឹកថ្នាំហៀរទៅឆ្អិនជាប់នឹងថ្មបេះចេញមិនបានវត្ថុខ្លះទ្រាំនឹងកម្តៅមិនបាន ខ្លះក៏បែរជាបែករបេះ ក៏ប៉ុន្តែយ៉ាងហោចណាស់ក៏លទ្ធផលនៅសល់ប្រើប្រាស់បានមិនតិចជាង៨០% ទេ។ អ្នកដែលបានបញ្ជាទិញរូបចម្លាក់សូន្យរូបមានការពេញចិត្តនិងស្នាដៃលោក យ៉ារី ហើយទទួលយកវត្ថុដែលខ្លួនបានបញ្ជានាំទៅផ្ទះពោរពេញដោយភាពសោមនស្ស ៕


Add some Sparkle to any room of the house this season & shop at...

**CONSIGNMENT CORNER**

**ហាងដែលលោកអ្នកអាចមកទិញរបស់ថ្មី ឬរបស់ប្រើបន្ត**
**ទិញបានរបស់ប្រើប្រាស់ល្អ ហើយតម្លៃថោក**

- Furniture, Bureaus
- Kitchen Sets
- Lots of Small Table
- Mirrors
- Dishes Sets
- Glass Ware
- Cake Plates

- មានបរិក្ខាការិយាល័យ
- គ្រឿងប្រើប្រាស់ក្នុងផ្ទះបាយក្រាន
- តុតូចៗមួយចំនួន
- កញ្ចក់តាំងជញ្ជាំង
- សិតចាន កែវ ទទួលភ្ញៀវ
- ចាសដាក់នំ... ។ល។

- Vintage Ornaments
- Byers Choice
- Lenox-Waterford
- Hummels
- Jewelries
- Sleds
- Lots of Sparkle
- Ceramic Trees
- Outdoor Ornaments

- គ្រឿងតាំងលម្អក្នុងផ្ទះគ្រប់យ៉ាង
- ដើមឈើលម្អធ្វើពីចាន ឬកែវ
- គ្រឿងតាំងលម្អក្រៅផ្ទះពេលបុណ្យទាន

យើងមានវត្ថុតាំងលម្អគ្រប់ផ្ទុន សំរាប់តាំងតុ ពិធីបុណ្យ ឱ្យមានសោភ័ណភាព និងភាពអឹកធឹក

8,000 SQ Ft.
978-251-7130
Open Wed-Sun.
បើកហាងពីថ្ងៃពុធដល់អាទិត្យ
17 Groton Road – Route 40. North Chelmsford, MA
Check us out at: www.consignmentcorner.net

**New Asia Restaurant**

343 Market Street. Lowell, MA 01852
(Corner of the New Asia Market) 978-441-6363





ភោជនីយដ្ឋានទើបបើកថ្មី! សូមអញ្ជើញមកពិសារម្ហូបអាហាររសជាតិឆ្ងាញ់
ធ្វើដោយចុងភៅចំណាន មានបទពិសោធន៍យូរឆ្នាំ តម្លៃថោកសមរម្យ

GRAND OPENING

**បំរើដោយម្ហូបខ្មែរ_ថៃ_ឡាវ_វៀតណាម និងចិន**



**ម្ហូបពិសេស!**
- សម្លរឆ្នាំងភ្លើង
- គោឡើងភ្នំ
- ភ្លាអង់ស្ងារ( តាមរបៀបបារាំង)
- ភ្លាត្រីសាល់ម៉ុន
- អាំងត្រីសាល់ម៉ុនស្វាយខ្ចី

*បញ្ជាមុខម្ហូប !
*ឬពិសារ "ប៊ុហ្វេថ្ងៃត្រង់" ពីម៉ោង១១ដល់៣ក្នុងតម្លៃតែ $7.50

**Special Lunch Buffet (11-3 p.m)**
**7.50 per person**



Open 7 Days a Week
9 a.m. – 9 p.m.

# លក់ហាងពាណិជ្ជកម្ម

**អាចបើកលក់គ្រឿងទេសធ្វើម្ហូបខ្មែរ និងហាងធ្វើ នំចាខ្វៃ នៅឡូវែលរដ្ឋម៉ាសាឈូសែត**

**OPEN CAMBODIAN GROCERY/ BAKERY IN LOWELL, MA**

**មានគ្រឿងបរិក្ខាររាប់ទាំងចង្ក្រាន និងម៉ាស៊ីនធ្វើនំប៉័ងផង**

(EQUIPMENT INCLUDED KITCHEN AND BAKE MACHINE)
WELL ESTABLISHED BUSINESS
FREE FRONT PARKINGS





**ASKING PRICE: $85,000**
**CALL (978) 996-7259 FOR SHOWINGS.**




## Business for sale

**LOCATES IN PAILIN PLAZA**
**BUSY TRAFFIC AREA**
**នៅក្នុង"ប៉ៃលិនប្លាសា"**
**...តំបន់មានមនុស្សចេញចូលច្រើន**
716 Middlesex St.
Lowell, MA




**មានលក់ ស្បង់ ចីវរ សំរាប់ព្រះសង្ឃ**

មានលក់សាច់ស្រស់ ត្រីស្រស់ ក្តាម ក្ដាម កង្កែប មានបន្លែស្រស់ គ្រប់មុខ ពិសេសមានបន្លែតម្រូវម្ហូបខ្មែរ-លាវ មានផ្លែឈើអាស៊ី គ្រប់យ៉ាង ដូចជាផ្លែម្កាក់ សាវម៉ាវ ផ្លែស្វាយ ផ្លែជំពូរ ខ្នោរ ទាបបារាំង ទាបស្រិត ផ្លែមង្ឃុត ផ្លែមាន ផ្លែស្រកានាគ ។ល។មានលក់ម្ហូបស្ងួត ក្នុងកញ្ចប់ នៅខាងក្រៅ ឬក្នុងទូទឹកកកគ្រប់មុខ មានលក់របស់របរ ប្រើប្រាស់ក្នុងផ្ទះ ។

**ពិសេស:** មានជ្រូកខ្វៃ ទាខ្វៃ មាន់ស្ងោដាក់ខ្ទឹម មាន់ទឹកស៊ីអ៊ីវ ត្រីចៀន ត្រីខ ទឹកអំពៅកៀប នំបាវនំបាំង

បង្អែមញ៉ាំកំសាន្តផ្សេងៗ។

**មានកាសែតខ្មែរ**
**រៀងរាល់ពីរអាទិត្យ**







Open: Mon-Sat:
9am-8pm
Sun:9am-7pm

475 Flatbush Avenue. Harford, CT 06106
Tel:(860)953-5458 -Fax:(860)953-5462

# ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ
# រ.ជ.រ.ប.ខ លោកតា សឺន សាន



**ដោយ : ម៉ម យឹន**

**(តពីលេខមុន)**

ខោអាវមួយចំនួនសម្រាប់ផ្តល់ឱ្យរួចជាស្រេច ហើយដែរ ជួយដល់អ្នកកាសែតទាំងនោះ ។

ការទទួលបានរៀបចំរួចជាស្រេចបាច់ហើយ ចាប់ផ្តើមធ្វើដំណើរត្រឡប់ទៅកាន់ទីប្រជុំជនមួយនៃដែនដីថៃ ក៏បានទៅដល់ទីនោះប្រមាណម៉ោង៣ជិតភ្លឺដោយមានរថយន្តទូបន្ទុកទេសចរណ៍ដ៏ប្រណិត១គ្រឿងចាំទទួលដឹកនាំយកភ្នាក់ងារសារព័ត៌មានមួយក្រុមនេះ ទៅកាន់ក្រុងបាងកកជាបន្ទាន់ដែរ ដែលមានអមដោយមន្ត្រីទទួលបន្ទុកកិច្ចការបរទេសរបស់រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរទៅជាមួយផងដែរ ។

ចាប់តាំងពីពេលដែលប្រើយុទ្ធសាស្ត្រថ្មីនេះមកសកម្មភាពប្រតិបត្តិការសឹកវាយប្រយុទ្ធទៅលើកងទ័ពខ្មែរយួនបានប្រព្រឹត្តទៅជាប់រហូតកងកម្លាំង កជរបខ ទាំងកងៗបានបញ្ជូនចូលទៅក្នុងផ្ទៃប្រទេសបន្ថែមទៀតជារៀងរាល់ថ្ងៃ ។ ពីព្រោះ



នៅក្នុងភូមិស្រុក និងក្រុងមានក្រុមសម្ងាត់បានជ្រៀតចូលទៅរស់នៅបានយ៉ាងស្ងប់សុខ ហើយប្រជាពលរដ្ឋក៏បានដឹង និងយល់អំពីគោលការណ៍គោលបំណងនៃរណសិរ្សជាតិ និងកងកម្លាំងកជបរខ ដែលចង់រំដោះប្រទេស និងសង្គ្រោះបំរើការពារប្រជាពលរដ្ឋខ្មែរឱ្យបានឯករាជ្យ និងសុខសន្តិភាពឡើងវិញ ។

ចំណែកភ្នាក់ងារយកព័ត៌មានអន្តរជាតិជាច្រើនតែងតែតាមដានសកម្មភាពប្រតិបត្តិការណ៍សឹកនេះកាន់តែច្រើនឡើងៗជាលំដាប់លំដោយដែរ ។

**តទៅលេខក្រោយ**


ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ អង្គរ

(Since 1991) ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ-អង្គរ

Angkor International Travel Agency




ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ សេវាអន្តោប្រវេសន៍
សេវាលិខិតឆ្លងដែន កក់សណ្ឋាគារ ឬជួលឡាន

**USA**
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

**Cambodia Office: Victory Travel (Skin Belle)**
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR,CHINA, ASIANA KOREAN AILINES

ក្រុមហ៊ុនធានារ៉ាប់រងដែលបាន
បំរើសង្គម២២ឆ្នាំហើយ

CONWAY INSURANCE



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត
មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

www.ConwayInsurance.com

សូមសួររក Philip Muth, Philip@ConwayInsurance.com

East Coast Center

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com



Skin Care Products | Tummy Tuck | Breast Lift | Beast Enlargement



Nose Surgery | Eyelid Surgery | Face Lift | Dermabrasion

ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន
អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ
កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។
និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត

381 West Broadway South Boston, MA 02127
(617) 464 - 0001

# សំណោកកោះកេរ...

Lynn, M A

(បទជាប់ទង)

គន់កោះត្រល់
កោះសំងំ
ពិនិត្រច្បាប់
ក្នុងឯកសារ
កោះកៀកកិត
ចោលត្រាតែ
កើតជាកូន
ពានរានការ
កោះត្រឡាច
កាយឆ្ងាយឃ្លាត
ឯកោះគត់
ស្តាយឥតល្ហែ

ខ្វល់នឹកស្រុក
ខំដង្ហោយ
ចាប់សំឡឹង
ត្រាបារាំង
ជិតកំពត
ផ្ដៃព្រៃនៅ
ពួនជាចៅ
បានកោះខ្មែរ
ខ្លាចញ័រខ្លួន
ឆ្ងៀតពុំបាន
ផុតពីដៃ
ប្រែប្រួលប្រាណ

មុខក្រៀមក្រំ
អោយខេមរា
ប្ដឹងតវ៉ា
តាំងអោយខ្មែរ ។
កោតមិនថៃ
ទៅពុំបាន
ផៅតិរច្ឆាន
កែឈ្មោះទៀត ។
ពួននឹក ញាតិ
ខានឃើញខ្មែរ
ថៃលួចកែ
បានទៅគេ ។

(អត្ថបទកំណាព្យចម្លងចេញពីសៀវភៅ
កំណាព្យសរសេរដៃ "បេះដូងកេរ")


## Foodtruck Business for Sale

**ឡានលក់ម្ហូបសម្រាប់លក់ចំណូល៥០០០ដុល្លារ ក្នុងមួយអាទិត្យបើក៥ថ្ងៃ**

Income: 5,000 dollars a week. Open only 5 days!
Location: 17th street and Spring Garden -Philadelphia
Contact: **215 586 1030**






Agent: Roeut Chak


# PK Property, Inc.

## ក្រុមហ៊ុនអចលនវត្ថុ លក់ ដួល គ្រប់ប្រភេទ

ភីខេ ប្រភីធី (215) 635-5100
Roeut Chak - (267)872-3516
409 West Cheltenham Avenue
Melrose Park, PA 19027

**សម្រាប់បើកភោជនីយដ្ឋានខ្មែរ**

- 5706 N. 5th Street, Philadelphia PA 19120

ពីដើមជាភោជនីយដ្ឋាន ឥឡូវបិទ២០០០sqft បន្ទប់ដេកបី ជាន់ទី២ជា Apt គ្រឿងបរិក្ខាទាំងអស់នៅក្នុងផ្ទះឈ្នួល២០០០/ខែ

5734 N.2nd Street, Philadelphia, PA 19120

២៥០០ sqft ពីដើមជាភោជនីយដ្ឋាន មានកន្លែងចតឡាន៧៥- ឈ្នួល ២១០០/ខែ

**កន្លែងភ្នាក់បៀរ** BEER DELI

- $16000/wk, Phila, Asking $99,000w/ Real Estate
- $13000wk, Phila., Asking $79,000w/ Real Estate
- $9000/wk, Asking $320.000
- $13,500/wk Asking $42000

**កន្លែងបោកគក់ដាក់កាត** **Co. Laundry**

- 100 Machines, 4500 sqft Asking $170,000 .
- $4500/wk Asking $200000
- 500/wk Bucks County; Asking $350,000

**កន្លែងចែកចាយបៀរ** Beer Distributor

- $1.3 Mil/yr, Bucks County, $250000 yearly income, Asking $1,150,000
- $75000/yr Philadelphia Asking $790,000 with RE
- 11,000,000 Philadelphia Asking $430,000

**សាឡុងធ្វើក្រចក** **Nail Salon**

- $18000/wk, Montgomery County, Asking $380,000
- $15000/wk South Jersey Asking $370,000

**សូមចូលទៅវេបសាយ**

www.pkpropertyinc.com to check more listings and office information.



# ផ្សារអាត្លង់ទិក

Atlantic Market

135 main St, Danbury, CT 06810

**203-830-3068**




ផ្សារនេះមានម្ចាស់ឈ្មោះ **ជាន់ ស៊ីខ** បើកលក់ដូរតាំងពី១០ឆ្នាំមកហើយ ជាពិសេសយើងជាអ្នកលក់ត្រីស្រស់ៗនៅក្នុងក្រុង ។ បន្ថែមពីលើលក់ត្រីស្រស់ យើងមានលក់បន្លែសម្រាប់ម្ហូបអាស៊ី ។

**យើងទទួលយក :** American Express -លុយសុទ្ធ -Debit card -Master Card -Visa

**បើកទ្វារ :** ថ្ងៃច័ន្ទ ម៉ោង ៩:៣០ព្រឹក ដល់៧ល្ងាច/ ថ្ងៃអង្គារ៍ ដល់ថ្ងៃសៅរ៍ ៩:៣០ដល់៨ល្ងាច/ ថ្ងៃអាទិត្យ ៩:៣០-៧:០០

**ទីផ្សារតថយន្តឥតគិតថ្លៃ**



## តើអំណោយអ្វីដ៏ល្អបំផុត ដែលអ្នកអាចឲ្យទៅកូនរបស់អ្នក នៅរដូវនេះ?

## សេចក្តីសន្យាថាគេនឹងមានការថែទាំសុខភាព នៅពេលគេត្រូវការវា។

ការធានារ៉ាប់រងសុខភាព ដោយឥតគិតថ្លៃ
ឬថោកថ្លៃ សំរាប់ក្មេងៗ និងក្មេងជំទង់ៗ
ដែលពុំបានធានារ៉ាប់រង។



ដាក់ពាក្យសុំនៅថ្ងៃនេះ តាមលេខ
**1-888-888-1211**
TTY 1-877-454-8477

chip Pennsylvania's Children's Health Insurance Program
www.chipcoverspakids.com

Kidz PARTNERS HEALTH PARTNERS
www.kidzpartners.com

## ANGKOR AUTO SERVICE,INC.
## ហាងជួសជុលរថយន្ត "អង្គរ"

**Free Estimate**

**Auto Body and Maintenance**



**BODY WORKS**
**Auto glass and windshields**
**Auto Frame Straightening and Painting**

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ីរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425



## ហាងខ្មែរជួសជុលរថយន្ត

### បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

# Rathe's Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងក៏រិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

# ទៅមើលបាល់ទាត់ សាលាឯកជននៅម៉ាសាឈូសេត

▸ សាលាឯជននៃសិស្សទេពកោសល្យខ្ពស់ពីរគឺ សាលា គ្រោតុន និងសាលាសាំងម៉ាក (Groton Schoot vs St Marks) បានធ្វើការប្រកួតផ្តាច់ព្រាត់ កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២ នៅទីលានបាល់ទាត់សាលាគ្រោតុន ។ គ្រោតុនឈ្នះរហូតដល់ទីបញ្ចប់ជួបជាមួយនឹងសាំងម៉ាក បានឈ្នះ២ ទល់នឹង ១ ហើយទទួលពានរង្វាន់ប្រចាំឆ្នាំយ៉ាងសង្ហា ។

ឆ្នាំនេះសាលាគ្រោតុនមានសិស្សថ្មីម្នាក់ក្នុងក្រុមមានដើមកំណើតខ្មែររស់នៅឡូវែល ទើបនឹងបានទទួលអាហារូបករណ៍ឱ្យចូលរៀនថ្នាក់ទី១០ ក្នុងសាលាដ៏ទំនើបនៃវិទ្យាល័យគ្រោតុនសិស្សនោះឈ្មោះ ថាយល័រស (Tylor Sar) អាយុ១៦ឆ្នាំ។ ថាយល័រ មានជំនាញពីរ ១-ខាងកីឡាបាល់ទាត់ ២-រៀនពូកែនៅសាលា។ ថាយល័រជាជំហរកណ្តាលនៃក្រុមទាត់បាល់សាលារបស់ខ្លួន ប្រកួត៩ដងរួចហើយ ឆ្នាំនេះពុំមានចាញ់ ឬស្មើម្តងណាសោះមិត្តភ័ក្តិរួមក្រុមមានការរីករាយនឹងទទួលមិត្តខ្មែរថ្មីដែលបានផ្តល់កម្លាំងថ្មីឱ្យក្រុម ។ ថ្ងៃប្រកួតបញ្ចប់នោះមានមាតាបិតាមិត្តភ័ក្តិនឹងអ្នកចូលចិត្តកីឡាបានឃើញការប្រកួតមួយដែល

**តទៅទំព័រទី ០៧**









• BEER
• WINE
• COFFEE

# SOC TRANG
**VIETNAMESE RESTAURANT**

**413 736-9999**

113 VERMONT STREET. SPRINGFIELD, MA 01108




យើងមានសេចក្តីរីករាយ និងសូមអញ្ជើញលោកអ្នកព្រមទាំងគ្រួសារ អញ្ជើញមកពិសារម្ហូបពិសេស ចំអិនដោយចុងភៅដ៏ជំនាញរបស់យើង និងលំហែរកាយនៅសាលពិសារភោជនាហារ ដែលរៀបចំយ៉ាងប្រណិតសំរាប់ទទួលលោកអ្នក ។

**ACCEPTING NEW PARTY BOOKINGS, ASSOCIATION MEETINGS, BIRTHDAYS ETC 200 PEOPLE CAPACITY.**



**ម្ហូបពិសេស**

- ▸ មានហ្វើ -មានគុយទាវ -មានបាយស្រូប មានគ្រឿងក្លែម
- ▸ មានបំរើភេសជ្ជៈស្រាបៀ និងភេសជ្ជៈមានសុរាតិច

**ទទួលកក់ពិធីជប់លៀង ឬ ធ្វើការប្រជុំរបស់សមាគម ឬ ធ្វើបុណ្យខួបកំណើត... (ឱ្យខ្ចីសាលមិនគិតថ្លៃ _យកតែថ្លៃបំរើម្ហូប)**

**Open Monday-Sunday**
**9 a.m. – 9 p.m.**
**Closed Thursdays**

**SPECIALS:**
*PHO * NOODLES *RICE COMBO
*SERVE BEER, LIGHT ALCOHOL DRINKS.

# ដំណើរកម្សាន្តខេត្តក្រុងនៅតាម បណ្តោយទន្លេមេគង្គ



ភ្ញៀវទេសចរបរទេសជិះទូកលំហែកាយតាមដងទន្លេមេគង្គ







០០០ការធ្វើដំណើរកម្សាន្តនៅលើបណ្តោយខ្សែទឹកដងទន្លេមេគង្គដោយជិះទូកនេះក្រសែភ្នែករបស់អ្នកទេសចរនឹងបានពើបប្រទះនូវទិដ្ឋភាពប្លែកៗក៏ដូចជាសម្រស់ទេសភាពធម្មជាតិដ៏ស្រស់ត្រកាលជាច្រើនក្នុងនេះ ក៏មានទិដ្ឋភាពនៃការប្រកបរបរចិញ្ចឹមជីវិតដោយការនេសាទត្រីនៅលើផ្ទៃទឹកទន្លេរបស់បងប្អូនប្រជាពលរដ្ឋយើង ។ ក្នុងរយៈពេលមិនយូរប៉ុន្មានយើងនឹងទៅដល់ក្នុងទឹកដីនៃទីរួមខេត្តកំពង់ចាមប្រកបដោយសុវត្ថិភាព ។ នៅពេលបានចូលមកដល់ទឹកដីនៃទីរួមខេត្តនេះភ្លាមអារម្មណ៍របស់យើងក៏បាននឹកឃើញទៅដល់កំណប់មនោសញ្ចេតនាអតីតកាលជាច្រើនដែលបន្សល់ទុកតាមរយៈទឹកដៃនិពន្ធទំនុកច្រៀងដោយកវីរៀមច្បង និងការច្រៀងរៀបរាប់ដោយវលកសំនៀងគ្មានគូប្រៀបរបស់អធិរាជសំឡេងមាស ស៊ីន ស៊ីសាមុត ក្នុងនេះមានដូចជាបទ "កំពង់ចាមកំពង់ចិត្ត" និងបទ "អក្ខរាតាមព្រះពាយ"ជាដើម ។ ដើម្បីរំលឹកនូវអនុស្សាវរីយ៍ទាំងនេះយើងក៏អាចធ្វើដំណើរកម្សាន្តទៅលំហែកាយ និងទស្សនាទេសភាពធម្មជាតិនៅលើស្ពាន Kizona រួចទើបបន្តដំណើរទៅកាន់តំបន់មាត់កំពង់មុខវត្តជីដុះទៀត ។ នៅទីនេះយើងឃើញទឹកទន្លេជន់ឡើងយ៉ាងល្ហល្ហាច ។ អ្នកស្រុកនៅទីនេះប្រាប់ថា សម្រាប់រដូវទឹកទន្លេមេគង្គឡើងយ៉ាងដូច្នេះយើងមិនអាចទស្សនាឆ្នេរខ្សាច់ និងទិដ្ឋភាពផ្សេងៗនៅលើស្ពានប្រជីសប្ញស្សីនាតំបន់កោះប៉ែនដ៏ស្រស់ស្អាតបានទេ ។

ថ្ងៃបន្ទាប់យើងបន្តដំណើរតាមទូកចាកចេញពីទឹកដីនៃទីរួមខេត្តកំពង់ចាមឆ្ពោះតាមបណ្តោយដងទន្លេមេគង្គលើទៅកាន់ទឹកដីខេត្តដែលគេស្គាល់ជាទូទៅតាមរយៈបទចម្រៀង "រំដួលក្រចេះ" របស់លោក អ៊ឹង សុងសឹម ។ ការធ្វើដំណើរនេះ យើងនឹងឃើញទេសភាព និងទិដ្ឋភាពផ្សេងៗដែលបានកើតមានឡើងនៅពីមុខក្រសែភ្នែករបស់យើងសុទ្ធតែពោរពេញដោយភាពស្រស់ត្រកាលគួរឱ្យចាប់ចិត្តគយគន់ជាទីបំផុត ។ ក្រោយពេលបានចូលមកដល់ក្នុងទឹកដីនៃទីរួមខេត្តក្រចេះ ហើយនោះយើងក៏បានបន្តដំណើរតាមទូកទៅកាន់តំបន់រមណីយដ្ឋានអភិរក្សសត្វផ្សោតកាំពីដែលស្ថិតនៅចម្ងាយប្រមាណ៧គ.មប៉ុណ្ណោះពីទីរួមខេត្តនេះ ។

ទីរមណីយដ្ឋាននេះជាតំបន់ទេសចរណ៍មានសក្តានុពលខ្លាំងរបស់ខេត្តក្រចេះក្នុងការទាក់ទាញភ្ញៀវទេសចរ ព្រោះមានសត្វផ្សោតទឹកសាបសម្រាប់ឱ្យភ្ញៀវទូទៅទស្សនា និងនៅចម្ងាយប្រមាណមួយគីឡូម៉ែត្រពីតំបន់នេះ នៅខែទឹកសម្រកមានកន្លែងកម្សាន្តមួយទៀតមានឈ្មោះថា រមណីយដ្ឋានកាំពីសម្រាប់បម្រើការងូតទឹកលេង និងលំហែកាយរបស់ភ្ញៀវទេសចរទូទៅបានយ៉ាងប្រសើរផងដែរ ។

ក្រោយពេលបានទស្សនាលំហែនៅតាមតំបន់រមណីយដ្ឋាន











មួយចំនួនរបស់ទឹកដីខេត្តក្រចេះរួចមកយើងក៏អាចបន្តដំណើរតាមទូកទៅកាន់ទឹកដីនៃខេត្តស្ទឹងត្រែងតាមបណ្តោយដងទន្លេមេគង្គលើដដែល ។ ក្នុងដំណើរកម្សាន្តនេះ យើងនឹងឃើញទេសភាព និងទិដ្ឋភាពផ្សេងៗនៅតាមសងខាងបណ្តោយដងទន្លេមេគង្គក្នុងទឹកដីនៃទីរួមខេត្តស្ទឹងត្រែងមានលក្ខណៈស្រស់ត្រកាល គួរឱ្យចាប់ចិត្តគយគន់ក្រៃលែង ។ នៅក្នុងទឹកដីនៃខេត្តស្ទឹងត្រែងមានមុខម្ហូបដែលល្បីឈ្មោះជាង គេគឺត្រីប៉ាសេអ៊ីមានរសជាតិឈ្ងុយឆ្ងាញ់ និងព្រមទាំងមានម្ហូបអាហារប្លែកមាត់ជាច្រើនទៀត របស់ជនជាតិឡាវផងដែរ ៕



ទូកទេសចរដឹកភ្ញៀវធ្វើដំណើរកម្សាន្តតាមដងទន្លេមេគង្គ